# មេរៀនទី ៦: ព្រះបន្ទូលគឺជាព្រះ

## យ៉ូហាន ១:១-១៨

**គោលបំណង៖** ព្រះអង្គតែងគង់នៅជាមួយយើងជានិច្ច។

**ខគម្ពីរចងចាំ៖ យ៉ូហាន១:១** *"កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**

កុមារអាចនឹងត្រៀមខ្លួនរួចជាស្រេចដើម្បីទទួលយកគំនិត ដែលថាព្រះទ្រង់គង់នៅជាមួយយើង។ ប៉ុន្តែដោយសារនេះគឺជាគំនិតតាមបែបអរូបី ដែលធ្វើឲ្យកុមារពិបាកយល់បានថា តើព្រះជាម្ចាស់ពិតជាបានគង់ជាមួយនឹងយើងពិតមែនតាមរបៀបណា។ ក្នុងនាមយើងជាគ្រូម្នាក់អ្នកគួរតែត្រៀមខ្លួនជាស្រេច ដើម្បីប្រាប់កុមារៗពីបទពិសោធន៍ផ្ទាល់ខ្លួនមួយចំនួនរបស់អ្នក អំពីរបៀបដែលព្រះគង់ជាមួយអ្នក។ សូមស្វែងរកវិធីណាដើម្បីឲ្យអ្នកអាចចែករំលែកពីសាច់រឿងរបស់អ្នក ទៅកាន់សិស្សក្នុងម៉ោងបង្រៀនណាមួយ និងត្រូវស្វែងរកឱកាសដើម្បីធ្វើយ៉ាងណាឲ្យកុមារអាចចែករំលែកបទពិសោធន៍របស់ពួកគេវិញផងដែរ។ សូមអរគុណសំរាប់ការបង្កើតនូវបរិយាកាសកក់ក្ដៅនៅក្នុងថ្នាក់រៀន ដើម្បីលើកទឹកចិត្តកុមារឲ្យចែកចាយសាច់រឿងរបស់ពួកគេ។ ការនេះនឹងប្រទានពរចំពោះសេចក្ដីជំនឿដល់កុមារ ដែលអ្នកកំពុងតែបង្រៀន និងដឹកនាំពួកគេ។

**ចំរៀង៖** ១. បើទ្រង់គង់ជាមួយ ២. ព្រះយេស៊ូវគឺជាព្រះអម្ចាស់ ៣. ខ្ញុំនិងទុកចិត្តទ្រង់

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «តើអ្នកឃើញអ្វី?» (ព្រះតែងតែគង់ជាមួយយើង)**

**សម្ភារៈដែលត្រូវការ៖** ទឹកមួយពែងធំលាយជាមួយក្រូចឆ្មារ(លាយឲ្យជូរ) និងពែងតូចៗសំរាប់កុមារភ្លក្ស។



១. បង្ហាញពែងទឹក (មានទឹកក្រូចឆ្មារនៅខាងក្នុង) ហើយសួរកុមារថា តើពួកគេឃើញអ្វីខ្លះ? កុមារនឹងឆ្លើយ "ទឹក" (ធ្វើយ៉ាងណាកុំឲ្យកុមារដឹងថា មានទឹកក្រូចឆ្មារនៅក្នុងទឹកនោះ)

២. បន្ទាប់មកសុំអ្នកស្ម័គ្រចិត្តមួយចំនួនមកភ្លក្សទឹកនោះ។

៣.សួរកុមារតើទឹកដែលគេផឹកនោះមានរសជាតិអ្វី? ពួកគេនឹងឆ្លើយថា "ក្រូចឆ្មារ"។

៤. សូមពន្យល់ប្រាប់កុមារថា ទោះជាគេមិនឃើញក្រូចឆ្មារនៅក្នុងទឹកក៏ដោយតែវានៅក្នុងទឹកនោះ។ ដូចគ្នាដែរ ទោះបីយើងមិនអាចមើលឃើញព្រះនៅពីមុខយើងក៏ដោយ ក៏ព្រះតែងតែគង់នៅទីនោះជានិច្ច។

**៤. ការណែនាំមេរៀន**

តើប្អូនកំពុងស្នាក់នៅក្នុងផ្ទះជាមួយនរណាខ្លះរាល់ថ្ងៃនេះ?(ទុកឲ្យកុមារឆ្លើយ) តើប្អូនមានអារម្មណ៍បែបណានៅពេលពួកគាត់នៅជាមួយប្អូនៗ?(ទុកឲ្យកុមារឆ្លើយ)

ថ្ងៃនេះអ្នកគ្រូចង់ប្រាប់ប្អូនៗថា ទោះបីជាប្អូនមិនមានឪពុកម្ដាយ បងប្អូន ឬសាច់ញាតិ នៅជាមួយក៏ដោយ ក៏ប្អូននៅតែមានម្នាក់ដែលតែងតែនៅជាមួយនឹងប្អូនជានិច្ច។ តើប្អូនដឹងទេថាគាត់ជាអ្នកណាដែរឬទេ? តោះយើងនឹងរៀនពីបុគ្គលម្នាក់នោះនៅក្នុងព្រះគម្ពីរជាមួយគ្នា។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃនេះយើងនឹងរៀនអំពីព្រះអង្គទ្រង់គង់ជាមួយយើង។ ប្រសិនបើយើងអានព្រះគម្ពីរ **យ៉ូហាន ១:១** បានចែងថា “កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជា “ព្រះ” កាលពីដើមដំបូងឡើយតើ “ព្រះបន្ទូល” ជាអ្នកណា? ព្រះគម្ពីរបានប្រាប់ថា “ព្រះបន្ទូល” នៅជាមួយនឹងព្រះហើយ “ព្រះបន្ទូល” នោះជាព្រះ!

ក្នុងគម្ពីរ **យ៉ូហាន ១:១៤** បាននិយាយថា “ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា” គឺមានន័យថា “ព្រះបន្ទូល” គឺជាព្រះយេស៊ូវ។ បើទោះបីទ្រង់ជាព្រះក៏ដោយ ក៏ព្រះយេស៊ូវបានយាងមកយកកំណើតជាមនុស្សដូចជាពួកយើងដែរ ។ ព្រះយេស៊ូវជាព្រះ ប៉ុន្តែជំនួសឲ្យការរស់នៅលើឋានសួគ៌ ព្រះអង្គបានយាង ចុះមករស់នៅជាមួយយើងវិញ! ទ្រង់ធ្វើបែបនេះដើម្បីជួយសង្គ្រោះ យើងនិងរំលឹកយើងថាព្រះអង្គតែងតែគង់នៅជាមួយយើងជានិច្ច។

ព្រះអង្គចង់ឲ្យយើងជឿដោយគ្មានការសង្ស័យថា ទ្រង់គង់ជាមួយយើង។ នៅពេលដែលយើងទុកចិត្តថា ព្រះអង្គគង់ជាមួយយើង នោះអ្វីៗនឹងត្រលប់ទៅជាមានផ្លូវដោះស្រាយ ហើយនៅចុងបញ្ចប់នឹងប្រែទៅជារឿងល្អឡើងវិញ ទោះបីជាបញ្ហាទាំងនោះមើលទៅដូចជាមិនសូវល្អក៏ដោយ ទាំងនេះគឺដោយសារយើងមានកំឡាំងពីព្រះជាម្ចាស់ បើទោះបីជាយើងមិនអាចមើលព្រះឃើញដោយភ្នែករបស់យើងក៏ដោយ តែយើងអាចដឹងថាព្រះអង្គគង់នៅជាមួយយើងតាមរយៈការឆ្លើយតបរបស់ទ្រង់នៅពេលយើងអធិស្ឋាន។ ជួនកាលយើងអាចទទួលនូវអារម្មណ៍ពីក្ដីស្រឡាញ់ និងវត្តមានរបស់ព្រះ ហើយជួនកាលក៏យើងមិនមានអារម្មណ៍ទាំងនោះដែរ។ យើងអាចមានអារម្មណ៍ថាយើងដូចជានៅតែម្នាក់ឯង នៅពេលយើងភ័យខ្លាច បាក់ទឹកចិត្ត មានជំងឺ ត្រូវមិត្តភក្តិ ឬឪពុកម្ដាយបោះបង់ចោល។ ឬក៏អាចជាពេលដែលគ្រូរបស់យើងមិនបានយកចិត្តទុកដាក់ជាមួយយើង ដែលធ្វើឲ្យយើងមានអារម្មណ៍ថាគ្មានអ្នកណាម្នាក់អាចជួយយើងបានឡើយ។ គ្រប់ពេលដែលមានបញ្ហាទាំងនោះគឺជាពេលដែលយើងត្រូវតែមានជំនឿថា ព្រះអង្គទ្រង់គង់ជាមួយយើង ពីព្រោះទ្រង់បានសន្យាថានឹងគង់ជាមួយយើងគ្រប់ពេល។

សូមគិតពីពេលវេលាដែលព្រះបានយកចិត្តទុកដាក់ចំពោះអ្នក ទោះបីជាអ្នកមិនអាចមើលឃើញទ្រង់ក៏ដោយ។ ព្រះអង្គតែងតែគង់ជាមួយយើង ហើយទ្រង់នឹងតែងតែមើលថែយើង។

## ៦. សំនួរពិភាក្សា

១. តើនៅក្នុងគម្ពីរ **យ៉ូហាន ១:១** បាននិយាយថាព្រះបន្ទូលជាអ្វី? *ជាព្រះ*

២. តើនៅក្នុងគម្ពីរ **យ៉ូហាន ១:១៤** បាននិយាយថាមានអ្វីកើតឡើងចំពោះព្រះបន្ទូល?
*ព្រះបន្ទូលបានត្រឡប់ទៅជាសាច់ឈាម ហើយគង់នៅជាមួយយើង*

៣. តើនៅពេលណាដែលអ្នកមានអារម្មណ៍ថាដូចជាព្រះកំពង់គង់ជាមួយអ្នក? *សូមឲ្យកុមារឆ្លើយ*

៤. តើអ្នកគួរធ្វើអ្វីខ្លះ នៅពេលដែលអ្នកមានអារម្មណ៍ថាឯកាហើយគ្មាននរណាម្នាក់ជួយអ្នក?
*ច្រៀង អានគម្ពីរ និងអធិស្ឋានទៅកាន់ព្រះ សូមចាំព្រះអង្គបានសន្យាថាទ្រង់តែងតែគង់ជាមួយយើង*

## ៧. ល្បែងកំសាន្ត « តើព្រះសង្គ្រោះមានលក្ខណៈដូចម្តេច?»

**ជំពីសទី១៖** « បើកភ្លើង និងបិទភ្លើង»




ព្រះយេស៊ូវមានបន្ទូលថា ព្រះអង្គគឺជាពន្លឺនៃលោកីយ៍។ សូមពន្យល់ប្រាប់កុមារថាពេលភ្លើងបើកពួកគេអាចរាំបាន ពីព្រោះវាជាសញ្ញាប្រាប់ថា ព្រះយេស៊ូវគង់ជាមួយពួកគេ។ ប៉ុន្តែនៅពេលដែលភ្លើងបិទ ពួកគេត្រូវតែបញ្ឈប់ការរាំរបស់ពួកគេ បើសិនពួកគេនៅតែបន្តរាំ គឺពួកគេនឹងចាញ់ល្បែងនេះ។



**ជំពីសទី២៖** «បិទភ្នែក និងបើកភ្នែក»

ប្រសិនបើនៅក្នុងព្រះវិហារមិនមានភ្លើង អ្នកក៏អាចឲ្យក្មេងលេងល្បែងនេះបានដូចគ្នា ដោយឲ្យកុមាររាំនៅពេលគេបើកភ្នែក ហើយឲ្យពួកគេឈប់រាំនៅពេលគេបិទភ្នែក។

## ៨. ខគម្ពីរចងចាំ យ៉ូហាន ១:១

## ៩. ហត្ថកម្ម ផាត់ពណ៌ - យ៉ូហាន ១:១

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# ផាត់ពណ៌



យ៉ូហាន ១៖១

កាលដើមដំបូងមានព្រះបន្ទូល
ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ
ហើយព្រះបន្ទូលនោះ ឯងជាព្រះ។